បើលោកអ្នក គ្រួសារលោកអ្នក មិត្តភក្តិ ឬ អតិថិជនណាមួយមានបញ្ហាអន្តោប្រវេសន៍ សូមទូរស័ព្ទទៅកាន់សេវាផ្តល់ឱវាទតាមទូរស័ព្ទរបស់យើង - ពត៌មានលំអិតមាននៅខាងក្នុង។

ដើម្បីទទួលពត៌មានលំអិតអំពីការហ្វឹកហ្វឺនដែលទទួលស្គាល់ជាផ្លូវការសំរាប់ភ្នាក់ងារកិច្ចការអន្តោប្រវេសន៍ ការបណ្តុះបណ្តាលវិជ្ជាជីវៈបន្តទៅទៀត ឬការអប់រំសហគមន៍ សូមទូរស័ព្ទក្នុងអម្លុងពេលម៉ោងធ្វើការ។

**Refugee & Immigration Legal Centre Inc**

Level 1, 121-123 Brunswick St
Fitzroy VIC 3065

ទូរស័ព្ទ : (03) 9413 0101
ទូរសារ : (03) 9413 0144
អ៊ីមែល : rilc@rilc.org.au

www.rilc.org.au

ទូរស័ព្ទផ្តល់ឱវាទ : **(03) 9413 0100**

ដើម្បីទទួលឱវាទ សូមទូរស័ព្ទនៅ
ថ្ងៃពុធ : **10** ព្រឹក – **4** ល្ងាច
ថ្ងៃសុក្រ : **2** រសៀល – **4** ល្ងាច

# rilc

# សាជីវកម្មមជ្ឈមណ្ឌលច្បាប់សំរាប់បញ្ហាជនភៀសខ្លួននិងអន្តោប្រវេសន៍

មជ្ឈមណ្ឌលច្បាប់សហគមន៍ដោយឥតគិតថ្លៃ

**refugee & immigration legal centre inc** (សាជីវកម្មមជ្ឈមណ្ឌលច្បាប់សំរាប់បញ្ហាជនភៀសខ្លួននិងអន្តោប្រវេសន៍)

Refugee & Immigration Legal Centre Inc គឺជាឈ្មោះថ្មីរបស់អង្គការទាំងពួងនៅក្នុងរដ្ឋវិកតូរីយ៉ា ដែលត្រូវបានស្គាល់កាលពីគ្រាមុនថាជា Refugee Advice & Casework Service (Aust) Inc (RACS) (សាជីវកម្មសេវាករណីកិច្ចការ និង ឱវាទសំរាប់ជនភៀសខ្លួន) និង Victorian Immigration Advice & Rights Centre (VIARC) (មជ្ឈមណ្ឌលផ្ដល់ឱវាទនិងសិទ្ធិអន្តោប្រវេសន៍វិកតូរីយ៉ា)។

RILC គឺជាមជ្ឈមណ្ឌលជំនួយផ្លូវច្បាប់សហគមន៍ឯករាជ្យដែលមានឯកទេសផ្លូវច្បាប់ គោលនយោបាយ និងទម្រង់ការសំរាប់បញ្ហាជនភៀសខ្លួននិងអន្តោប្រវេសន៍គ្រួសារ។ យើងផ្ដល់សេវា(កិច្ចបំរើ)ឱវាទតាមទូរស័ព្ទនិងឱវាទនៅពេលយប់ ទៅឲ្យករណីកិច្ចការទាំងអស់និងជាបន្តទៅទៀតដល់ជនទាំងឡាយដែលករណីរបស់ខ្លួនមានលក្ខណៈសមរម្យ និងមិនអាចទទួលសេវាពីទីកន្លែងផ្សេងទៀត។

RILC ចូលរួមនៅក្នុងកម្មវិធីសកម្មមួយនៃការកែទម្រង់ច្បាប់ ដើម្បីធ្វើឲ្យប្រាកដថា កម្មវិធីអន្តោប្រវេសន៍និងជនភៀសខ្លួនរបស់ប្រទេសអូស្ត្រាលី ធ្វើប្រតិបត្តិការនៅក្នុងលក្ខណៈត្រឹមត្រូវនិងសមរម្យ។ យើងក៏ចាត់ចែងឲ្យមានវគ្គសិក្សាដែលទទួលស្គាល់ជាផ្លូវការសំរាប់គោលបំណងចុះឈ្មោះជាភ្នាក់ងារកិច្ចការអន្តោប្រវេសន៍ ការប្រជុំបណ្ដុះបណ្ដាលវិជ្ជាជីវៈបន្តទៅទៀត និង សម័យប្រជុំអប់រំសហគមន៍ផងដែរ។

ចំណុចតទៅនេះ ប្រាប់អំពីកិច្ចការផ្សេងៗដែលយើងធ្វើ :

- ការធានាយកគូស្រករ គូដណ្ដឹង កូន និង សមាជិកឯទៀតរបស់គ្រួសារ មកពីបរទេស
- ដាក់ពាក្យសុំផ្លាស់ប្ដូរឋានៈសំរាប់អ្នកដែលស្វែងរកការរស់នៅជាអចិន្ត្រៃយ៍ នៅក្នុងប្រទេសអូស្ត្រាលី
- ដាក់ពាក្យសុំទិដ្ឋាការការពារ (ឋានៈជាជនភៀសខ្លួន) នៅក្នុងប្រទេសអូស្ត្រាលី
- ឱវាទទៅឲ្យអ្នកទាំងឡាយដែលស្វែងរកការសុំដាក់បញ្ចូលអ្នកនៅបរទេស ចូលទៅក្នុងកម្មវិធីជនភៀសខ្លួន និង មនុស្សធម៌ពិសេស
- ឱវាទទៅកាន់អ្នកដែលជាប់ឃុំនៅក្នុងកន្លែងឃុំឃាំងអន្តោប្រវេសន៍
- ឱវាទអំពីលក្ខណៈវិនិច្ឆ័យទិដ្ឋាការអន្តោប្រវេសន៍ឯទៀត ដោយមានរួមទាំងទិដ្ឋាការចូលមកសាជាថ្មីឬវិលមកវិញ
- ឱវាទអំពីលក្ខខណ្ឌដែលភ្ជាប់នឹងទិដ្ឋាការទាំងពួង ដូចជាការអនុញ្ញាតឲ្យធ្វើការ និង សិទ្ធិទទួល Medicare
- ការតំណាង និង គាំទ្រនៅក្នុងករណីទាំងឡាយនៅចំពោះមុខ Department of Immigration & Multicultural Affairs (ក្រសួងកិច្ចការអន្តោប្រវេសន៍ ហើយនិងពហុវប្បធម៌និងជនជាតិដើម)
- បណ្ដឹងឧទ្ធរណ៍និងការធ្វើតំណាងនៅពេលឡើងទៅកាន់សាលាក្ដីអន្តោប្រវេសន៍
- ឱវាទទៅកាន់ជនអន្តោប្រវេសន៍ដែលស្នាក់នៅហួសពេល និងខុសច្បាប់ផ្សេងទៀត
- ការបញ្ជូនសំរាប់ពិគ្រោះឱវាទនិងជំនួយ អំពីបញ្ហាសុខុមាលភាពសង្គមដែលពាក់ព័ន្ធ ដូចជាទីលំនៅ ប្រាក់ជំនួយសង្គមកិច្ច និងការពិគ្រោះឱវាទសំរាប់អ្នកនៅរស់ពីទារុណកម្មនិងការប៉ះពាល់ផ្លូវចិត្តជាខ្លាំង។

## សេវាឱវាទតាមទូរស័ព្ទ

សេវានេះផ្ដល់ឱវាទតាមទូរស័ព្ទ តាមរយៈការទូរស័ព្ទទៅលេខ (03) 9413 0100 ហើយសួររកមេធាវីប្រចាំការ។ ពេលម៉ោងផ្ដល់ឱវាទតាមទូរស័ព្ទ មានដូចតទៅនេះ :

ថ្ងៃពុធ : 10 ព្រឹក – 4 ល្ងាច
ថ្ងៃសុក្រ : 2 រសៀល – 4 ល្ងាច

## សេវានៅពេលយប់

<u>តាមការណាត់ជួបតែប៉ុណ្ណោះ តាមរយៈសេវាផ្ដល់ឱវាទតាមទូរស័ព្ទ</u>។ ពេលម៉ោងមានដូចតទៅនេះ :

យប់ថ្ងៃច័ន្ទ : 6:30 យប់ និង 7 យប់

ហើយធ្វើនៅឯ :

Level 1, 121-123 Brunswick St
Fitzroy VIC 3065

## សេវាពេលថ្ងៃ

<u>សំរាប់អតិថិជនគ្រាសព្វថ្ងៃតែប៉ុណ្ណោះ</u>។ ដោយសារតែថវិកាមានកំរិតកំណត់ យើងអាចផ្ដល់ការណាត់ជួបទៅឲ្យអតិថិជនរបស់យើងនៅគ្រាសព្វថ្ងៃតែប៉ុណ្ណោះ។